**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ការិយាល័យ**
**អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ..........០៣០/០១៩.......... **នពរ**

# សេចក្តីថ្លែងការណ៍

**ការិយាល័យអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា** សូមគោរពជម្រាបជូនដល់សាធារណជនទាំងនៅក្នុង និងក្រៅប្រទេសថា ការលើកឡើងក្នុងរូបភាពញុះញង់ដោយក្រុមនៅឯនាយសមុទ្រ បានអំពាវនាវដល់កងកម្លាំងប្រដាប់អាវុធ ក៏ដូចជាប្រជាពលរដ្ឋ ក្នុងបំណងបង្កើតកម្លាំងចលនាមហាជនប្រឆាំងនឹងច្បាប់ ប្រឆាំងនឹងរាជរដ្ឋាភិបាល ដែលបានកើតចេញពីការបោះឆ្នោតស្របច្បាប់រួចមកហើយ និងកំពុងដំណើរការប្រកបដោយប្រក្រតីភាព ស្ថិតនៅក្នុងនីត្យានុកូលភាពពេញលេញ។ សកម្មភាពនេះចាត់ទុកជាការប្រព្រឹត្តបទឧក្រិដ្ឋ ឬជាសកម្មភាពឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

**ការិយាល័យអ្នកនាំពាក្យ** យល់ឃើញថា ការញុះញង់ខាងលើ គឺជាអំពើភេរវកម្មនយោបាយប្រឆាំងទៅនឹងផលប្រយោជន៍កម្ពុជា ក៏ដូចប្រជាពលរដ្ឋរបស់ខ្លួន ទោះសកម្មភាពញុះញង់នោះស្ថិតនៅឯនាយសមុទ្រ និងអាចជះឥទ្ធិពល ក៏ដូចជាកើតមាននៅក្នុងប្រទេសកម្ពុជាជាយថាហេតុបែបណាក៏ដោយ។ រាជរដ្ឋាភិបាលនឹងចាត់វិធានការម៉ឺងម៉ាត់ តាមផ្លូវច្បាប់គ្រប់យ៉ាង រួមទាំងកិច្ចសហការអន្តរជាតិ ក្នុងការទប់ស្កាត់សកម្មភាពភេរវកម្មនយោបាយទាំងនេះ។

**ការិយាល័យអ្នកនាំពាក្យ** ក៏សូមបញ្ជាក់សារជាថ្មីថា សកម្មភាពភេរវកម្មនយោបាយនេះ បង្កើតជាសង្គ្រាមចិត្តសាស្ត្រនយោបាយ ប្រឆាំងពិតប្រាកដនឹងភាពសុខសាន្ត និងប្រក្រតីភាព ដែលជាជម្រើសអាទិភាពរបស់មហាជនខ្មែរ។ សកម្មភាពភេរវកម្មនយោបាយនេះ ប្រឆាំងនឹងដំណើរការច្បាប់កម្ពុជា ប្រឆាំងនឹងរបបប្រជាធិបតេយ្យ កំពុងអភិវឌ្ឍក្នុងភាពទៀងទាត់តាមច្បាប់កំណត់ជាធរមាន ដើម្បីថែរក្សាលើកស្ទួយសន្តិភាព និងស្ថិរភាពនយោបាយ ដែលជាទិសដៅដ៏មានសារៈសំខាន់បំផុតរបស់កម្ពុជា មិនអាចងាករេបាន។

**រាជរដ្ឋាភិបាល** កំពុងតាមដានយ៉ាងយកចិត្តទុកដាក់ និងស្និទ្ធបំផុត ចំពោះរាល់សកម្មភាព និងចលនាវិទ្ធង្សនារបស់បុគ្គល ឬក្រុមពាក់ព័ន្ធទៅនឹងសកម្មភាពភេរវកម្មនយោបាយទាំងនេះ។

អាជ្ញាធរមានសមត្ថកិច្ច បាននិងកំពុងត្រៀមជាស្រេច ក្នុងការឆ្លើយតបជាមួយនឹងការប្រមូលភស្តុតាងជាក់ស្តែង និងកំណត់អត្តសញ្ញាណលើបុគ្គលពាក់ព័ន្ធ ដើម្បីអនុវត្តច្បាប់ ដែលសមាមាត្រឆ្លើយតបនឹងសកម្មភាពភេរវកម្មនយោបាយ នៅពេលចាំបាច់ណាមួយ៕

ថ្ងៃសុក្រ ៤កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩